# ទំនុកសេចក្ដីទុកចិត្តលើព្រះអម្ចាស់

មានទំនុកដំកើងជាច្រើនសំដែងពីមានទំនុកទុកចិត្តយ៉ាងជ្រាលជ្រៅក្នុងព្រះ និងសេចក្ដីល្អរបស់ទ្រង់។ ការសំដែងបែបនេះមានច្រើននៅក្នុងទំនុកដំកើង ហើយអាចរកឃើញនៅក្នុងប្រភេទផ្សេងៗនៃទំនុកដំកើង។ ទោះជាយ៉ាងនេះក្ដី ទស្សនៈនៃការទុកចិត្តមានយ៉ាងច្រើននៅក្នុងចំពូកចំនួនតិចនៅក្នុងកណ្ឌទំនុកដំកើង ដែលបានបង្ហាញពីការជឿជាក់ទុកចិត្តលើព្រះអម្ចាស់។ បទពិសោធន៍គឺជាគ្រូដ៏ចំណានក្នុងការបង្រៀនពីសេចក្ដីជឿជាក់ទុកចិត្តនេះ។

## និយមន័យ និងការបរិយាយពីទំនុកសេចក្ដីទុកចិត្ត

នៅពេលខ្លះ និងកន្លែងខ្លះ អ្នកទំនុកដំកើងបាននៅក្នុងស្រមោលនៃសេចក្ដីទុក្ខវេទនា នោះទំនុកសេចក្ដីទុកចិត្តគឺត្រូវការចាំបាច់នៅក្នុងស្ថានភាព និងពេលវេលានោះ។ តែនៅក្នុងកណ្ឌទំនុកដំកើង យើងមិនអាចតែងតែដឹង ឬកំណត់ពីវិបត្ត ដែលនាំឲ្យអ្នកទំនុកដំកើងប្រកាសសេចក្ដីទុកចិត្តលើព្រះអម្ចាស់ ប៉ុន្តែជាទូទៅ អ្នកទំនុកដំកើងនិយាយពី ទុក្ខនៅកន្លែងស្ងាត់កំបាំង នៅតាមផ្លូវរបស់អ្នកទំនុកដំកើង។ មិនដូចទំនុកអរព្រះគុណ ដែលអ្នកទំនុកដំកើងបាននិយាយពីវិបត្ត ហើយបន្ថែមនូវការធានាអះអាងពីថា វិបត្តនោះបានកន្លងផុតទៅ ទំនុកសេចក្ដីទុកចិត្តធ្វើការប្រកាសនូវការទុកចិត្តលើព្រះអម្ចាស់ ប៉ុន្តែពួកគាត់មិនតែងតែបង្ហាញពីស្ថានភាពច្បាស់លាស់ពីការ ដែលធ្វើឲ្យគាត់ប្រកាសទំនុកសេចក្ដីទុកចិត្តនេះទេ។ ពួកគាត់ភាគច្រើនផ្ដល់តំរុយតែប៉ុណ្ណោះ។ ឧទាហរណ៍ ទំនុកដំកើង ២៧ និយាយតំរុយពីស្ថានភាពចំបាំង ដែលជាការដែលជំរុញឲ្យអ្នកទំនុកដំកើងប្រកាសពីទំនុកសេចក្ដីទុកចិត្តលើព្រះអម្ចាស់៖

*ទោះបើមានពួកពលមកបោះទ័ពច្បាំងនឹងខ្ញុំ*
*គង់តែចិត្តខ្ញុំមិនភ័យឡើយ*
*ទោះបើកើតមានចំបាំងទាស់នឹងខ្ញុំ*
*គង់តែខ្ញុំនឹងមានចិត្តសង្ឃឹមបានដែរ*
(៣ និង ៦ផងដែរ)

ស្រដៀងគ្នាដែរ ទំនុកដំកើង ២៣ និយាយពីអ្នកទំនុកដំកើងបានឡោមព័ទ្ធដោយសត្រូវ ("*ទ្រង់រៀបតុនៅមុខទូលបង្គំ ចំពោះពួកខ្មាំងសត្រូវផង*" ៥)។ ប្រហែលជា ការនោះ គឺជា "*ច្រកភ្នំនៃម្លប់សេចក្ដីស្លាប់*" ហើយនៅក្នុងស្ថានភាពនោះ គាត់បានប្រកាសនូវទំនុកទុកចិត្ត។ នៅពេលដែល គ្មានការពណ៌នាច្បាស់លាស់ពិតប្រាកដនូវវិបត្តជាក់លាក់ នៅតែមានតំរុវជំនួយខ្លះៗក្នុងការសិក្សាពីស្ថានភាព ដែលបណ្ដាលឲ្យអ្នកទំនុកដំកើងទុកចិត្តលើព្រះ។

ទុកជាយ៉ាងនេះក្តី នៅមានស្ថានភាពច្បាស់លាស់។ ការនេះមាននៅក្នុង ទំនុកដំកើង ៦២ ជាទីដែល អ្នកទំនុកដំកើងប្រាប់ពីអស់អ្នក ដែលព្យាយាមធ្វើឲ្យគាត់វិនាសៈ

*"តើអ្នករាល់គ្នានឹងសង្កត់ញូចូលទៅលើមនុស្ស*
*ទាំងចង់សំឡាប់គេដល់កាលណាទៀត*
*ប្រៀបដូចជាកំផែងដែលទ្រេត ដូចជារបងដែលចង់រលំហើយ*
*គេប្រឹក្សាគ្នា ដើម្បីតែនឹងទំលាក់អ្នកនោះចុះពីយសរបស់ខ្លួន*
*គេចូលចិត្តនឹងសេចក្តីភូតភរ មាត់គេឲ្យពរ*
*តែនៅក្នុងចិត្ត គេប្រទេចផ្តាសាវិញ"* (៦៣-៤)។

យើងបានរកឃើញនូវភាសាដូចគ្នាទៅនឹង ទំនុកដំកើង ៧៣ ដែលពណ៌នាពីអ្នកទំនុកដំកើងមាន ការព្រួយបារម្ភចំពោះការរីកចំរើនរបស់មនុស្សអាក្រក់ៈ

*"តែឯជើងទូលបង្គំ បានកន្ទេកចេញហៀបនឹងផុតទីហើយ*
*ជំហាននៃទូលបង្គំបានហៀបនឹងរត់លត្អាត់ទៅ*
*ដ្បិតទូលបង្គំមានសេចក្តីច្រណែនចំពោះមនុស្សអំនួត*
*ដោយឃើញសេចក្តីចំរើនរបស់មនុស្សអាក្រក់នោះ"* (៦២-៣)។

ពិតណាស់ ការនោះហើយ ដែលជាបញ្ហា ដែលជំរុញឲ្យអ្នកទំនុកដំកើង ចូលទៅក្នុងទីបរិសុទ្ធនៃ ការទុកចិត្ត ជាទីដែលគាត់បានរកឃើញសេចក្តីធូរស្បើយខាងផ្លូវចិត្ត (៧៣:១៧)។

ទំនុកសេចក្តីទុកចិត្តបង្ហាញនូវបញ្ហា ដែលអ្នកទំនុកដំកើងមាន ហើយយើងរំពឹងគិតថា នឹងមានការរអ៊ូរទាំ ច្រើន ប៉ុន្តែមិនមានដូច្នោះទេ។ ជំនួសឲ្យការយំសោកនៅក្នុងស្ថានភាពណាមួយនៅក្នុងជីវិតរបស់អ្នកទំនុកដំកើង នោះពួកគាត់ឈរ ហើយមើលលើសពីការយំសោក ដោយមានសេចក្តីទុកចិត្ត និងមានសេចក្តីសង្ឃឹមជឿជាក់ តែក៏ផ្ទុយពីទំនុកអរព្រះគុណ គឺថា គាត់មិនទាន់រួចផុតពីវិបត្តរបស់គាត់នៅឡើយទេ។ ប៉ុន្តែ អ្នកទំនុកដំកើងអាច ប្រឈមមុខចំពោះបញ្ហាវិបត្តនោះបាន នាពេលឥឡូវនេះ ពីព្រោះបទពិសោធន៍របស់គាត់បានបង្រៀនដល់គាត់ថា ព្រះអម្ចាស់តែងតែល្អ ហើយនឹងឆ្លើយតបចំពោះសេចក្តីអធិស្ឋាន នៅពេលកូនរបស់ទ្រង់ស្រែករកទ្រង់។ ទំនុកដំកើងបែបទាំងនេះ គឺជាការសំដែងចេញនូវសេចក្តីជំនឿ មិនមែនការប្រកាសជោគជ័យនោះទេ។ ការទាំងនោះត្រួសត្រាយផ្លូវ នាំទៅរកជោគជ័យ តែពិតប្រាកដនោះ ការទាំងនោះមិនបានន័យថា បានជោគជ័យ ពិតប្រាកដនោះដែរ។ ទំនុកសេចក្តីទុកចិត្តនៅក្នុងបេះដូងរបស់អ្នកថ្វាយបង្គំព្រះនៅសម័យកាលនោះ ហើយ បង្ហាញពីជីវិតខាងវិញ្ញាណ ដែលអាចរក្សាពួកគេឲ្យឈរមាំមួនក្នុងព្រះអង្គ ក្នុងពេលដែលគេរស់នៅក្នុងពិភពនៃ ការឈឺចាប់ និងចលាចល។ នៅក្នុងខ្សែជីវិតរបស់គាត់ ក្នុងគ្រប់ទាំងស្ថានភាពលំបាក នោះយើងឃើញបដានៃ សេចក្តីជំនឿរបស់គាត់បង្ហាញចេញឲ្យគ្រប់ៗគ្នាបានឃើញ។

## លក្ខណៈនៃទំនុកសេចក្តីទុកចិត្ត

**១. ការប្រកាសពីសេចក្តីទុកចិត្ត**

អ្នកទំនុកដំកើងនឹងប្រកាសពីសេចក្តីទុកចិត្តលើព្រះអម្ចាស់

**២. សេចក្តីអញ្ជើញឲ្យទុកចិត្ត ឬសង្ឃឹម**

ការនេះមិនតែងតែបង្ហាញមាននៅក្នុងទំនុកសេចក្តីទុកចិត្តទេ ប៉ុន្តែ វាមាននៅក្នុងទំនុកដំកើងមួយចំនួនផងដែរ ដូចជា ទំនុកដំកើង ៤:៤, ៥; ២៧:១៤ និងនៅក្នុងទំនុកសេចក្តីទុកចិត្ត ៦២:៨ និង ១១៥:៩-១១។

**៣. មូលដ្ឋានចំពោះសេចក្តីទុកចិត្ត**

ជួនកាល អ្នកទំនុកដំកើងបានទទួលចំណេះដឹង និងគោលការណ៍ខាងវិញ្ញាណ ដែលគាត់បានសង្កេតឃើញ ឬបទពិសោធន៍ ដែលបានបង្រៀនគាត់ ជាមេរៀនសេចក្តីជំនឿ។

**៤. ការសុំ**

នេះគឺជាសេចក្តីអធិស្ឋាននៃសេចក្តីជំនឿ។ ឧទាហរណ៍ អ្នកទំនុកដំកើងដឹងថា ព្រះគឺជាព្រះពេញដោយសេចក្តីមេត្តាករុណា ហើយទ្រង់អាចបង្ហាញសេចក្តីមេត្តាករុណាម្តងទៀត៖ ១២៣:២-៣

**៥. ការប្តេជ្ញា ឬសន្យាសរសើរព្រះអម្ចាស់** (១៦:៧; ២៧:៦ខ; ១១៥:១៧-១៨)។

សេចក្តីសន្យានេះបានលេចឡើងចេញពីជម្រៅនៃសេចក្តីជំនឿ ដែលថា ព្រះនឹងស្តាប់ការអំពាវនាវរបស់គាត់ និងមកជួយសង្គ្រោះគាត់។

**៦. ការប្រកាសសេចក្តីទុកចិត្ត**

## ប្រភេទទំនុកសេចក្តីទុកចិត្ត

**១. ទំនុកសេចក្តីទុកចិត្តបែបបុគ្គលភាព**

ទំនុកសេចក្តីទុកចិត្តបែបបុគ្គលភាពមាន ទំនុកដំកើង ៤, ១៦, ២៣, ២៧, ៦២ និង៧៣។

**២. ទំនុកសេចក្តីទុកចិត្តបែបសហគមន៍**

ទំនុកសេចក្តីទុកចិត្តបែបសហគមន៍ មាន ទំនុកដំកើង ៩០, ១១៥, ១២៣, ១២៤, ១២៥ និង១២៦។